**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

21

**ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

លេខ.....០៣៥៤....បទ.រន.បម...........

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវសៀវភៅលេខកូដប្រៃសណីយ៍ឆ្នាំ២០១៧

( Postal Code Directory 2017 )

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ មានកិត្តិយសសូមជម្រាបជូនដំណឹង ដល់គ្រប់ក្រសួង ស្ថាប័ន អង្គភាព សហគ្រាស ប្រតិបត្តិករប្រៃសណីយ៍ និងសាធារណៈជន មេត្តាជ្រាបថា អនុលោមតាមខ្លឹមសារប្រកាសរបស់ក្រសួង លេខ ៣០១ បទ.ប្រក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៧ ស្តីពីការកែសម្រួល និងបំពេញបន្ថែមលេខកូដប្រៃសណីយ៍ក៏ដូចជាសេចក្តីណែនាំរបស់សហភាពប្រៃសណីយ៍សកល (UPU) ក្រសួងនឹងដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវសៀវភៅលេខកូដប្រៃសណីយ៍ដែលបានកែសម្រួល និងបំពេញបន្ថែមក្នុងឆ្នាំ២០១៧ (Postal Code Directory 2017)ចាប់ពីថ្ងៃ១រោច ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១ ត្រូវនឹងថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៨ នេះតទៅជំនួសសៀវភៅលេខសម្គាល់តំបន់ប្រៃសណីយ៍ចាស់ដែលបានបោះពុម្ពកាលឆ្នាំ១៩៩៧។

ក្រសួងសង្ឃឹមថា សៀវភៅលេខកូដប្រៃសណីយ៍ថ្មីនេះ នឹងរួមចំណែកជំរុញការធ្វើទំនើបកម្មវិស័យប្រៃសណីយ៍ ជួយសម្រួលដល់ការបញ្ជូន ការបែងចែក និងការចែកចាយបញ្ញើតាមបណ្តាញប្រៃសណីយ៍ឱ្យកាន់តែប្រសើរឡើង។ ជាងនេះទៅទៀត ការកែសម្រួលនិងបំពេញបន្ថែមកូដប្រៃសណីយ៍នេះ បានឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការចាំបាច់ក្នុងការប្រើប្រាស់សេវាកម្មនានាតាមប្រព័ន្ធអ៊ីនធឺណិត ពិសេសពាណិជ្ជកម្មតាមបែបអេឡិកត្រូនិច(E-commerce)ដែលកាន់តែរីកដុះដាលឥតឈប់ឈរក្នុងនិន្នាការថ្មីនៃសង្គមសេដ្ឋកិច្ចឌីជីថល។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមបណ្តាក្រសួង ស្ថាប័ន អង្គភាព សហគ្រាស ប្រតិបត្តិករប្រៃសណីយ៍ និងសាធារណៈជន មេត្តាជ្រាបជាព័ត៌មាន និងសូមលើកទឹកចិត្តឱ្យប្រើប្រាស់លេខកូដប្រៃសណីយ៍ជាផ្លូវការតាមតម្រូវការប្រកបដោយប្រសិទ្ធភាព។

ថ្ងៃច័ន្ទ ១០ កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**ត្រាំ អ៊ីវតឹក**

អគារលេខ ១៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ទូរស័ព្ទ (៨៥៥) ២៣-៧២៤៨១០/៤២៦៥១០
ទូរសារ (៨៥៥) ២៣-៧២៤០៦៩